# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 01-Jul-2019, 13:28
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល តាមរយៈលោកក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង (វិធាន១០៦-២ និង ១០៨-១)

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ
## របស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២)

---

ដាក់ដោយ៖

**មេធាវីការពារក្តីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

ដាក់ជូន៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele Mwachande MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Phillip RAPOZA

ចៅក្រម យ៉ា ណារិន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Cécile ROUBEIX

កញ្ញា Marine BOUDJEMAA

កញ្ញា Dounia HATTABI

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**មេធាវីការពារក្តីលោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានប្រកាសថា លោក ខៀវ សំផន ជាប់ពិរុទ្ធពីបទប្រល័យពូជសាសន៍ (លើជនជាតិវៀតណាម) បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ហើយបានផ្តន្ទាទោសលោក ខៀវ សំផន ឱ្យជាប់ពន្ធនាគារអស់មួយជីវិត[1]។ អង្គជំនុំជម្រះបានបញ្ជាក់ថានឹងជូនដំណឹងអំពីសំអាងហេតុពេញលេញនៃសាលក្រមជាលាយលក្ខណ៍អក្សរ "ក្នុងពេលសមស្រប"[2]។

២. នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ មេធាវីការពារក្តីលោក ខៀវ សំផន ("មេធាវីការពារក្តី") បានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ហើយបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") ឱ្យធ្វើមោឃភាពសាលក្រម ដោយមូលហេតុវិការៈទម្រង់ និងគ្មានសំអាងហេតុ[3]។ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ តុលាការកំពូលបានសម្រេចមិនទទួលយកបណ្តឹងសាទុក្ខនេះ[4]។

៣. នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ មេធាវីការពារក្តីបានស្នើសុំធ្វើមោឃភាពសេចក្តីសម្រេចនេះ ដោយហេតុថា ក្រុមប្រឹក្សាចៅក្រម ដែលបានចេញសេចក្តីសម្រេចនៅពេលនោះ មានសមាសភាពមិនត្រឹមត្រូវតាមកំណត់ច្បាប់[5]។ អស់រយៈពេលជិតបីខែក្រោយមក តុលាការកំពូលនៅតែមិនបានជូនដំណឹងអំពីសំណើនេះ[6]។

---

[1] ប្រតិចារឹកសវនាការ ("ប្រតិចារឹក") ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E1/529.1** ទំព័រ ៣៨-៤២ ចន្លោះពីម៉ោង ១១:២៨ ដល់ម៉ោង ១១:៣៨។

[2] ប្រតិចារឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E1/529.1** ទំព័រ ៣ ប្រហែលម៉ោង ៩:៣៦។

[3] បណ្តឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ប្រឆាំងនឹងសាលក្រម ប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E463/1**។

[4] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្តីសង្ខេបនៃសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ **E463/1/3**។ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ មេធាវីការពារក្តីបានស្នើសុំឱ្យបកប្រែសេចក្តីសម្រេចជាភាសាបារាំង ដែលត្រូវបានជូនដំណឹងនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩។

[5] សំណើរបស់លោក ខៀវ សំផន សុំធ្វើមោឃភាពសេចក្តីសម្រេច E463/1/3 ទាក់ទងនឹងបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសាលក្រមប្រកាសថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩។

[6] សំណើនេះត្រូវបានដាក់នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ១១ និង ៥២ នាទី ប៉ុន្តែ នៅតែមិនទទួលបានការជូនដំណឹងនៅពេលបញ្ជូនសារណានេះទៅបកប្រែ។ សំណើនេះស្ថិតនៅក្នុងដៃរបស់ក្រឡាបញ្ជីតុលាការកំពូលនៅឡើយ។

៤. នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ភាគីបានទទួលសេចក្តីជូនដំណឹងអំពីសំអាងហេតុពេញលេញនៃសាលក្រមលើសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ កម្រាស់ ៤.១០១ ទំព័រ ជាភាសាខ្មែរ ២.៨២៨ ទំព័រ ជាភាសាបារាំង ២.៣៨៧ ទំព័រ ជាភាសាអង់គ្លេស (រួមទាំងឧបសម្ព័ន្ធ) និងកំណត់សម្គាល់ជើងទំព័រចំនួន ១៤.៤៤៦ ("សាលក្រមជាលាយលក្ខណ៍អក្សរ")[7]។

៥. នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ មេធាវីការពារក្តីបានស្នើសុំរយៈពេល ៨ ខែ និងកម្រាស់ ១០០ ទំព័រ សម្រាប់ការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ជាពីរភាសា ចំណែកឯមេធាវីការពារក្តីលោក នួន ជា បានស្នើសុំរយៈពេល ៦ ខែ និងកម្រាស់ ១០០ ទំព័រ សម្រាប់ការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[8]។ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ តុលាការកំពូលបានផ្តល់ជូនភាគីទាំងអស់នូវរយៈពេល ៣ ខែ និងកម្រាស់ ៦០ ទំព័រ[9]។

៦. នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ មេធាវីការពារក្តីបានស្នើសុំឲ្យពិនិត្យឡើងវិញលើសេចក្តីសម្រេចនេះ[10]។ អស់រយៈពេលជាងមួយខែក្រោយមក គឺនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ តុលាការកំពូលបានបដិសេធសំណើនេះ[11]។

៧. តាមរយៈសារណានេះ[12] មេធាវីការពារក្តីសូមដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសលោក ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២។

---

[7] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ("សាលក្រមជាលាយលក្ខណ៍អក្សរ)។

[8] សំណើរបស់លោក ខៀវ សំផន សុំពន្យារពេល និងបន្ថែមចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ F39/1.1 ("សំណើ F39/1.1"), សំណើបន្ទាន់លើកទីមួយរបស់ នួន ជា សុំចំនួនទំព័រ និងពេលវេលាបន្ថែមសម្រាប់ការដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ F40/1.1។

[9] សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រ សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ឯកសារ F43 ("សេចក្តីសម្រេច F43")។

[10] សំណើរបស់ លោក ខៀវ សំផន សុំឲ្យនិត្យឡើងវិញលើសេចក្តីសម្រេចស្តីពីការសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ ឯកសារ F44។

[11] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឲ្យពិចារណាឡើងវិញនូវសេចក្តីសម្រេចអំពីការស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រ លើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ F44/1 ("សេចក្តីសម្រេច F44/1")។

[12] ស្របតាមវិធាន ១០៤ និងវិធាន ១០៥ នៃវិធានផ្ទៃក្នុង។

៨. លោក ខៀវ សំផន ពុំមានពេលវេលា និងមធ្យោបាយចាំបាច់ សម្រាប់ការត្រៀមរៀបចំឯកសារដ៏សំខាន់នេះ ក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខនោះទេ ហើយស្ថិតក្នុងស្ថានភាពចាញ់ប្រៀបសហព្រះរាជអាជ្ញា។

៩. ដោយសារតែពេលវេលាប្រថុចប្រញ៉ុចពេក គ្មានសមាជិកណាម្នាក់នៃក្រុមមេធាវីការពារក្តីអាចធ្វើការវិភាគសាលក្រមជាលាយលក្ខណ៍អក្សរទាំងស្រុងទេ ដោយមិនចាំបាច់និយាយដល់ការផ្ទៀងផ្ទាត់ប្រភពនោះឡើយ។ សូម្បីតែលោក ខៀវ សំផន បានបំពានអនុសាសន៍របស់គ្រូពេទ្យ និងថែមទាំងធ្វើការដោយមិនគិតពីសុខភាពរបស់ខ្លួនក៏ដោយ[13] ក៏គាត់មិនអាចអានសាលក្រមជាលាយលក្ខណ៍អក្សរចប់ ដើម្បីពិភាក្សាឲ្យបានពេញលេញជាមួយក្រុមមេធាវីការពារក្តីរបស់គាត់បានទេ។

១០. ក្នុងលក្ខខណ្ឌផ្ទុយនឹងវិធានស្តីពីការជំនុំជម្រះក្តីដោយយុត្តិធម៌ មេធាវីការពារក្តីបានប្រឹងប្រែងស្វែងរកកំហុស ជាបច្ច័យនាំទៅដល់ការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោស និងសេចក្តីសម្រេចបន្ទាន់បន្ទំនានា ពាក់ព័ន្ធនឹងមូលដ្ឋានដែលអនុញ្ញាតឲ្យប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម។ ប៉ុន្តែ ដោយសារយើងមិនអាចធ្វើបានហួសពីលទ្ធភាព សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន ពិតជាមិនល្អឥតខ្ចោះ និងមិនគ្រប់ជ្រុងជ្រោយនោះទេ។

១១. ដោយសារតែពុំមានពេលវេលាគ្រប់គ្រាន់ មេធាវីការពារក្តីមិនអាចរៀបចំសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនេះ ស្របតាមបំណងប្រាថ្នារបស់ខ្លួនទេ។ អនុលោមតាមយុត្តិសាស្ត្ររបស់តុលាការកំពូល[14] មេធាវីការពារក្តីបានគូសបញ្ជាក់ដោយសង្ខេបនូវកំហុសនានា។ ដូច្នេះ មេធាវីការពារក្តីមិនបានបង្ហាញទឡ្ហីករណ៍ ឬពន្យល់ថាហេតុអ្វីបានជាកំហុសទាំងនេះធ្វើឲ្យសាលក្រម ឬសេចក្តីសម្រេចក្លាយជាមោឃៈ បណ្តាលឲ្យមានភាពមិនយុត្តិធម៌ និង/ឬបង្កព្យសនកម្មនោះឡើយ។ ប៉ុន្តែ

[13] ឧទាហរណ៍ សូមមើលរបាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍របស់លោក ខៀវ សំផន ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ ឯកសារ E13/442 (សម្ងាត់បំផុត)។

[14] សេចក្តីសម្រេច F43 កថាខណ្ឌ ១១ យោងដល់កថាខណ្ឌ ៨ នៃសេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ឯកសារ F3/3។ សូមមើលផងដែរ សេចក្តីសម្រេច F44/1 ទំព័រ ៤-៥៖ "ការរៀបចំសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ គឺជានីតិវិធីមួយក្នុងគោលបំណងកម្រិត (...) និងខ្លឹមសារ។

មេធាវីការពារក្តីសូមគូសបញ្ជាក់ថា ជាទូទៅ កំហុសអង្គច្បាប់ ដែលបានរកឃើញ កើតចេញពីការអនុវត្តច្បាប់ដោយមិនខ្វល់នឹងគោលការណ៍នីត្យានុកូលភាព ឬការអនុវត្តគោលការណ៍ដោយមិនត្រឹមត្រូវ ខណៈដែលច្បាប់ ឬគោលការណ៍ទាំងនេះត្រូវបានរម្លឹកយ៉ាងត្រឹមត្រូវ។ ដូច្នេះ កំហុសអង្គហេតុ ដែលបានរកឃើញ គឺជាផលវិបាកផ្ទាល់នៃច្បាប់ដែលត្រូវបានកំណត់ ឬអនុវត្តដោយមិនត្រឹមត្រូវ និងកើតចេញពីការវិភាគភ័ស្តុតាងដោយលម្អៀង និងមិនពេញលេញ ជាពិសេស តាមរយៈវិធីសាស្ត្របង្ហាញភ័ស្តុតាងដាក់បន្ទុកតែមួយមុខគត់។

១២. លើសពីនេះទៀត ដោយសារតែពុំមានលទ្ធភាពរិះគន់សាលក្រម កម្រាស់ ២.៨២៨ ទំព័រ ជាភាសាបារាំង ត្រឹមតែ ៣ ខែ ជាពីរភាសា និង ៦០ ទំព័រ មេធាវីការពារក្តីត្រូវបង្ខំចិត្តប្រើអក្សរកាត់ជាច្រើនដូចបានរៀបរាប់ក្នុងឧបសម្ព័ន្ធ។ មេធាវីការពារក្តីក៏សូមបញ្ជាក់ដែរថា កថាខណ្ឌនៃសាលក្រមជាលាយលក្ខណ៍អក្សរ ដែលលើកឡើងនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ រួមបញ្ចូលទាំងការសំអាង សេចក្តីសម្រេច និងការយោងនានា នៅក្នុងកំណត់សម្គាល់ជើងទំព័រ។ ម្យ៉ាងវិញទៀត កំហុស ដែលបានរកឃើញ ត្រូវបានបង្ហាញ ខុសពីប្លង់នៃសារណាបណ្តឹងសាទុក្ខ ប៉ុន្តែ តាមលំដាប់លំដោយនៃសាលក្រមជាលាយលក្ខណ៍អក្សរ។ ដូច្នេះ កំហុសខ្លះអាចត្រួតគ្នា ប៉ុន្តែ មេធាវីការពារក្តីពុំមានពេលស្រង់កំហុសត្រួតគ្នាទេ ជាពិសេស នៅពេលសេចក្តីសន្និដ្ឋានប្រហាក់ប្រហែលគ្នារបស់អង្គជំនុំជម្រះត្រូវបានផ្តល់សំអាងហេតុខុសៗគ្នា ទៅតាមផ្នែកផ្សេងៗនៃសាលក្រម។ ផ្ទុយមកវិញ កំហុសខ្លះ ដែលត្រូវបានបង្ហាញជាកំហុសតែមួយ តាមពិត ជាកំហុសច្រើនរួមគ្នា ឧទាហរណ៍ករណីនៃកំហុសអង្គហេតុដែលកើតចេញពីកំហុសអង្គច្បាប់ ក្នុងការពិនិត្យភ័ស្តុតាង។

១៣. ដោយសារពេលវេលាខ្លី មេធាវីការពារក្តីបានកំណត់នូវសេចក្តីសម្រេចបន្ទាន់បង្ខំ ដែលមិនត្រូវបានលើកឡើងនៅក្នុងសាលក្រមជាលាយលក្ខណ៍អក្សរ និងជាកម្មវត្ថុនៃការប្តឹងសាទុក្ខ ពីព្រោះសេចក្តីសម្រេចទាំងនេះមានផលប៉ះពាល់លើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ប៉ុន្តែ មេធាវីការពារក្តីមិនអាចបញ្ជាក់ថា តើសេចក្តីសម្រេចណាខ្លះមានកំហុសអ្វីខ្លះឲ្យបានច្បាស់លាស់នោះទេ ហើយត្រូវរៀបរាប់នៅក្នុងឧបសម្ព័ន្ធ។ ជាពិសេស សេចក្តីសម្រេចផ្ទាល់មាត់ចំនួន ១៥៩ និងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរចំនួន ១៩៦ ក្នុងនោះ ៧៤ ត្រូវបានចេញតាមសារអេឡិចត្រូនិច។

១៤. ម្យ៉ាងវិញទៀត មេធាវីការពារក្ដីមិនអាចរៀបចំបណ្ដឹងជំទាស់... 

១៥. នៅក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខនេះ ក្រៅពីសេចក្ដីសម្រេចបន្ទាន់បង្ខំចំនួន ៣៥៥ (នៅមានទៀត) ដែលត្រូវបានដាក់ជាឧបសម្ព័ន្ធ មេធាវីការពារក្ដីបានរកឃើញកំហុសរបស់អង្គជំនុំជម្រះចំនួន ១.៨២៤ ដែលត្រូវបានបង្ហាញដោយសង្ខេប និងគ្រាន់តែរៀបចំជាកំហុសបឋម (ផ្នែកទី I) និងជាកំហុស ទៅតាមប្លង់នៃសាលក្រមជាលាយលក្ខណ៍អក្សរ (ផ្នែកទី II)។

## I. កំហុសបឋម

១៦. អង្គជំនុំជម្រះសាលាដំបូងបានរំលោភលើវិធានគ្រឹះនៃការជំនុំជម្រះក្ដីដោយយុត្តិធម៌ ដោយបានប្រព្រឹត្ត ជាអាទិ៍នូវកំហុសដូចខាងក្រោម៖

**0.១** កំហុសអង្គច្បាប់៖ ពុំបានផ្ដល់សំអាងហេតុនៅថ្ងៃប្រកាសសាលក្រម។

**0.២-0.១៥** កំហុសអង្គច្បាប់ និងកំហុសនៃការប្រើឆន្ទានុសិទ្ធិ៖ អំឡុងពេលជំនុំជម្រះ និងដោយបានកាត់ទោស ខៀវ សំផន **ដោយរំលោភលើសិទ្ធិរបស់គាត់**៖ ក្នុងការទទួលបានការកាត់សេចក្ដីឱ្យបានឆាប់រហ័ស (**0.២**) សិទ្ធិទទួលបានតុលាការមួយដែលគោរពតាមបណ្ដឹងមកកាន់ខ្លួន/ដែលបង្កើតឡើងដោយច្បាប់ (**0.៣**) សិទ្ធិទទួលបានការជូនដំណឹងពីប្រភេទ និងសំអាងហេតុនៃការចោទប្រកាន់មកលើរូបគាត់ (**0.៤**) សិទ្ធិទទួលបានសច្ចភាពគតិយុត្ត និងនីតិវិធី (**0.៥**) សិទ្ធិទទួលបានតុលាការឯករាជ្យ និងមិនលំអៀង (**0.៦**) សិទ្ធិទទួលបានសច្ចធានិរទោស (**0.៧**) សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយចាំបាច់ក្នុងការរៀបចំការការពារខ្លួន (**0.៨**) សិទ្ធិទទួលបានការជំនុំជម្រះចំពោះមុខ (**0.៩**) សិទ្ធិសុំឱ្យរឿងក្ដីរបស់គាត់ត្រូវបានជំនុំ

[15] សំណើ F39/1.1 កថាខណ្ឌ ៣៥។

[16] ពេលបណ្ដឹងជំទាស់ប្រឆាំងនឹងចៅក្រមទាំងអស់ គណៈកម្មាធិការរដ្ឋបាលតុលាការត្រូវចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះពិសេសមួយ ពីក្នុងចំណោមចៅក្រមនៃ អ.វ.ត.ក ដើម្បីពិនិត្យលើបណ្ដឹងនោះ (វិធាន ៣៤(៦) នៃវិធានផ្ទៃក្នុង)។

ជម្រះ (០.១០) សិទ្ធិទទួលបានការការពារក្តីខ្លួនប្រកបដោយប្រសិទ្ធភាព (០.១១) សិទ្ធិទទួលបានតម្លាភាពក្នុងដំណើរការនីតិវិធី (០.១២) សិទ្ធិទទួលបានសំអាងហេតុនៃសេចក្តីសម្រេច និងសាលក្រម (០.១៣) សិទ្ធិទទួលបានសមភាពក្នុងការការពារក្តី (០.១៤) សិទ្ធិមិនត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោសចំពោះបទល្មើសដែលគាត់ធ្លាប់ត្រូវបានរួចផុតពីការចោទប្រកាន់ ឬសម្រេចទោសរួចហើយ (០.១៥)។

**០.១៦** កំហុសអង្គច្បាប់ និងកំហុសនៃការប្រើឆន្ទានុសិទ្ធិ៖ ពុំបើកសវនាការដេញដោលឡើងវិញ ក្រោយពីមានការដាក់បង្ហាញឯកសារ E319/71។

## II. <u>កំហុសដកស្រង់នៅតាមប្លង់ នៃសាលក្រមជាលាយលក្ខណ៍អក្សរ</u>

### <u>សេចក្តីផ្តើម</u>

១៧. នៅក្នុង**ផ្នែកទី ១** នៃសាលក្រមជាលាយលក្ខណ៍អក្សរ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តជាអាទិ៍នូវកំហុសដូចខាងក្រោម៖

**១.១** កំហុសអង្គច្បាប់៖ សេចក្តីសម្រេចលើចំណាត់ការនៃការចោទប្រកាន់នានាដែលនៅសល់ ដោយសេចក្តីសម្រេចនេះធ្វើឡើងយឺតពេល កថាខណ្ឌ ១៣។

**១.២** កំហុសអង្គច្បាប់៖ វិសាលភាពនៃឧក្រិដ្ឋកម្មរងការចោទប្រកាន់ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦។

### <u>បញ្ហាបឋម</u>

១៨. នៅក្នុង**ផ្នែកទី ២** នៃសាលក្រមជាលាយលក្ខណ៍អក្សរ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តជាអាទិ៍នូវកំហុសដូចខាងក្រោម៖

**២.១** កំហុសអង្គច្បាប់ និងអង្គហេតុ៖ យុត្តាធិការបុគ្គលលើរូប ខៀវ សំផន កថាខណ្ឌ ១៧-១៨។

**២.២** កំហុសអង្គច្បាប់៖ និយមន័យគោលការណ៍នីត្យានុកូលភាព និងការបដិសេធចោលទឡ្ហីករណ៍របស់ ខៀវ សំផន កថាខណ្ឌ ២០-៣២។

**២.៣** កំហុសអង្គច្បាប់៖ ការបដិសេធចោលទឡ្ហីករណ៍របស់ ខៀវ សំផន ទាក់ទងនឹងប្រភេទ និងតម្លៃ ហើយដែលទឡ្ហីករណ៍ទាំងនោះត្រូវបានចម្លងចេញពីសំណុំរឿង០០២/០១ មកដាក់ក្នុងសំណុំរឿង០០២/០២ កថាខណ្ឌ ៣៦។

**២.៤** កំហុសអង្គច្បាប់៖ភាពខុសគ្នា ជំនឿឥស្សរចិត្ត/ជំនឿហួសពីវិមតិសង្ស័យ កថាខណ្ឌ ៣៨-៤០។

**២.៥** កំហុសអង្គច្បាប់៖ ការធ្វេសប្រហែសចំពោះលក្ខណៈពិសេសនៃវិធាន ៨៧ (៤) កថាខណ្ឌ ៤៣។

**២.៦** កំហុសអង្គច្បាប់៖ ការសន្និដ្ឋានលើឯកសារទទួលបាន ធ្វើបណ្ណសារ និងរក្សាទុកដោយមជ្ឈមណ្ឌលឯកសារកម្ពុជា កថាខណ្ឌ ៤៦។

**២.៧** កំហុសអង្គច្បាប់៖ ការសន្និដ្ឋានលើឯកសារដែលត្រូវបានយោងនៅក្នុងដីកាដំណោះស្រាយ កថាខណ្ឌ ៤៦។

**២.៨** កំហុសអង្គច្បាប់៖ បន្ទុកក្នុងការជំទាស់ទៅនឹងការសន្និដ្ឋាន កថាខណ្ឌ ៤៦។

**២.៩** កំហុសអង្គច្បាប់៖ ការពិនិត្យលើការចោទប្រកាន់ ដើម្បីជំទាស់នឹងការសន្និដ្ឋាន កថាខណ្ឌ ៤៦។

**២.១០** កំហុសអង្គច្បាប់៖ ដោយអះអាងថា គ្រប់សាក្សីទាំងអស់សុទ្ធតែផ្តល់សក្ខីកម្ម ក្រោមពាក្យសម្បថ កថាខណ្ឌ ៥០ កំណត់សម្គាល់ជើងទំព័រ ២៩។

**២.១១** កំហុសអង្គច្បាប់៖ ភាពទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ កថាខណ្ឌ ៥១។

**២.១២** កំហុសអង្គច្បាប់៖ ការអានឡើងវិញនូវចម្លើយមុនៗ និងការសួរបញ្ជាក់ក្នុងអំឡុងពេលសវនាការ កថាខណ្ឌ ៥២។

**២.១៣** កំហុសអង្គច្បាប់៖ ការទទួលយកភ័ស្តុតាង និងការពិភាក្សាដេញដោលចំពោះមុខ កថាខណ្ឌ ៥៦។

**២.១៤** កំហុសអង្គច្បាប់៖ ភ័ស្តុតាងដែលត្រូវបានទទួលយក ក្រោយពីមានសំណើធ្វើឡើងអនុលោមតាមវិធាន ៨៧ (៤) កថាខណ្ឌ ៥៦។

**២.១៥** កំហុសអង្គច្បាប់៖ ការអាចចូលពិនិត្យមើលបាន និងតម្លៃជាភ័ស្តុតាងនៃឯកសារធ្វើឡើងនាសម័យកាលនោះ កថាខណ្ឌ ៥៧។

**២.១៦** កំហុសអង្គច្បាប់៖ ការសំអាងលើភ័ស្តុតាងស្ថិតនៅក្រៅវិសាលភាព កថាខណ្ឌ ៦០។

**២.១៧** កំហុសអង្គច្បាប់៖ ការពិនិត្យលើទឡ្ហីករណ៍ទាក់ទងនឹងតម្លៃជាភ័ស្តុតាងនៃធាតុផ្សំភ័ស្តុតាង កថាខណ្ឌ ៦១។

**២.១៨** កំហុសអង្គច្បាប់៖ កត្តាវាយតម្លៃលើតម្លៃជាភ័ស្តុតាងនៃធាតុផ្សំភ័ស្តុតាង កថាខណ្ឌ ៦១។

**២.១៩** កំហុសអង្គច្បាប់៖ ការវាយតម្លៃលើភាពជឿជាក់បានរបស់សាក្សី និងបុរេនិច្ឆ័យវប្បធម៌ កថាខណ្ឌ ៦២។

**២.២០** កំហុសអង្គច្បាប់៖ ដំណើរការទាញសេចក្តីសន្និដ្ឋាន និងភ័ស្តុតាងហួសពីវិមតិសង្ស័យ កថាខណ្ឌ ៦៤-៦៥។

**២.២១** កំហុសអង្គច្បាប់៖ ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី និងការវាយតម្លៃលើតម្លៃនៃសក្ខីកម្ម កថាខណ្ឌ ៦៧។

**២.២២** កំហុសអង្គច្បាប់៖ ការសំអាងលើដើមបណ្តឹងរដ្ឋប្បវេណីដែលរងផលប៉ះពាល់ផ្ទាល់ពីឧក្រិដ្ឋកម្ម កថាខណ្ឌ ៦៧។

**២.២៣** កំហុសអង្គច្បាប់៖ ការសំអាងលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ៦៩។

**២.២៤** កំហុសអង្គច្បាប់៖ ការទទួលយកកំណត់ហេតុ ជំនួសឱ្យការមកផ្តល់សក្ខីកម្មផ្ទាល់មាត់ កថាខណ្ឌ ៧០។

**២.២៥** កំហុសអង្គច្បាប់៖ ការទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីទទួលមរណភាព ឬមិនទំនេរ កថាខណ្ឌ ៧១-៧២។

**២.២៦** កំហុសអង្គច្បាប់៖ តម្លៃនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីទទួលមរណភាព ឬមិនទំនេរ កថាខណ្ឌ ៧១-៧២។

**២.២៧** កំហុសអង្គច្បាប់៖ ការប្រើប្រាស់ភ័ស្តុតាងបានមកដោយសារអំពើទារុណកម្ម កថាខណ្ឌ ៧៤-៧៨។

**២.២៨** កំហុសអង្គច្បាប់៖ ការមិនអនុវត្តជាប្រព័ន្ធនូវគោលការណ៍ដែលត្រូវបានរំលឹក/ចែង ក្នុងកថាខណ្ឌ ៣៦, ៣៨, ៤០, ៤៩, ៥៣, ៦០, ៦១, ៦២, ៦៣, ៦៤-៦៥, ៦៥, ៦៦, ៦៩, ៧១, ៧២, ៧៣, ១៩៤, ៣៤៤, ៣៥១, ៣៥៤, ៤៧០, ៤៧១, ៤៧២, ៤៧៩។

**២.២៩** កំហុសអង្គច្បាប់៖ ការពិនិត្យលើការចោទប្រកាន់ស្តីពីភាពមិនលំអៀង កថាខណ្ឌ ១១៣-១១៥។

**២.៣០** កំហុសអង្គច្បាប់៖ ការពិនិត្យលើទឡ្ហីករណ៍ទាក់ទងនឹងការមកផ្តល់សក្ខីកម្មរបស់សាក្សីដែលត្រូវបានស្នើសុំឱ្យកោះហៅ កថាខណ្ឌ ១២៦-១២៧។

**២.៣១** កំហុសអង្គច្បាប់៖ ការពិនិត្យលើទឡ្ហីករណ៍ទាក់ទងនឹងការបញ្ចូលភ័ស្តុតាងមកពីសំណុំរឿង ០០៣/០០៤ កថាខណ្ឌ ១៣៩-១៤៨។

**២.៣២** កំហុសអង្គច្បាប់៖ ការកំណត់បទចោទឡើងវិញ ពីការសម្លាប់រង្គាល មកជាអំពើមនុស្សឃាត/ចេតនាដោយប្រយោល កថាខណ្ឌ ១៥២-១៥៧។

**២.៣៣** កំហុសអង្គច្បាប់៖ ការស្នើសុំឱ្យពិនិត្យលើរឿងក្តី បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតបានស៊ើបសួរហួសពីបណ្តឹងដែលខ្លួនបានទទួល កថាខណ្ឌ ១៥៨-១៦៥។

**២.៣៤** កំហុសអង្គច្បាប់៖ ការស្នើសុំឱ្យពិនិត្យលើអង្គហេតុទាក់ទងនឹងការនិរទេស កថាខណ្ឌ ១៦៦-១៦៨។

**២.៣៥** កំហុសអង្គច្បាប់៖ ការស្នើសុំឱ្យពិនិត្យលើអង្គហេតុទាក់ទងនឹងការនិរទេសនៅសហករណ៍ត្រាំកក់ កថាខណ្ឌ ១៦៩។

**២.៣៦** កំហុសអង្គច្បាប់៖ ការស្នើសុំឱ្យពិនិត្យលើអង្គហេតុទាក់ទងនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងទាក់ទងនឹងអតីតទាហាន និងអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ កថាខណ្ឌ ១៧០-១៧៦។

**២.៣៧** កំហុសអង្គច្បាប់៖ ការស្នើសុំឱ្យពិនិត្យលើអង្គហេតុទាក់ទងនឹងពុទ្ធសាសនិក កថាខណ្ឌ ១៧៧-១៧៨។

**២.៣៨** កំហុសអង្គច្បាប់៖ ការស្នើសុំឱ្យពិនិត្យ បន្ទាប់ពីពុំមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៧៩-១៨០។

**២.៣៩** កំហុសអង្គច្បាប់៖ ការស្នើសុំឱ្យពិនិត្យលើអង្គហេតុទាក់ទងនឹងខ្មែរក្រោម និងភ័ស្តុតាង កថាខណ្ឌ ១៨១-១៨៥។

**២.៤០** កំហុសអង្គច្បាប់៖ ការស្នើសុំឱ្យពិនិត្យលើអង្គហេតុទាក់ទងនឹងការរំលោភផ្លូវភេទនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ កថាខណ្ឌ ១៨៦-១៨៨។

**២.៤១** កំហុសអង្គច្បាប់៖ ការស្នើសុំឱ្យពិនិត្យលើអង្គហេតុកើតក្នុងទឹកដីប្រទេសវៀតណាម និងភ័ស្តុតាង កថាខណ្ឌ ១៨៩-១៩០។

**<u>បរិបទប្រវត្តិសាស្ត្រ</u>**

១៩. នៅក្នុង**ផ្នែកទី ៣** នៃសាលក្រមជាលាយលក្ខណ៍អក្សរ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តជាអាទិ៍នូវកំហុសដូចខាងក្រោម៖

**ការបង្កើត និងការរីកចម្រើនរបស់ ប.ក.ក.**

**៣.១** កំហុសអង្គហេតុ៖ ការពិចារណាផ្តោតតែលើការបង្កើត និងការរីកចម្រើនរបស់ ប.ក.ក. ដើម្បីបង្ហាញឱ្យឃើញពីបរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៩១-២៣៥។

**៣.២** កំហុសអង្គច្បាប់៖ ការសំអាងលើសក្ខីកម្ម/សៀវភៅរបស់ជនជាប់ចោទ និងសាក្សីជាអ្នកជំនាញ កថាខណ្ឌ ១៩២-១៩៥។

**៣.៣** កំហុសអង្គច្បាប់៖ ការវាយតម្លៃលើចម្លើយ និងសំណេររបស់ ខៀវ សំផន កថាខណ្ឌ ១៩៤។

**៣.៤** កំហុសអង្គហេតុ៖ ចលនាជាតិដែលត្រូវបានរៀបចំឡើងវិញនៅក្នុងសមាជបក្សកុម្មុយនីស្តឥណ្ឌូចិន នាឆ្នាំ ១៩៥១ កថាខណ្ឌ ១៩៨។

**៣.៥** កំហុសអង្គហេតុ៖ បក្សប្រជាជនបដិវត្តន៍ខ្មែរហៀបនឹងរលាយ ក្រោយពីមានកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ នាឆ្នាំ១៩៥៤ កថាខណ្ឌ ១៩៩។

**៣.៦** កំហុសអង្គហេតុ៖ ចុងឆ្នាំ១៩៥៥ ការរៀបចំឡើងវិញនូវបក្សប្រជាជនបដិវត្តន៍ខ្មែរ ក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការមជ្ឈិម ដែលមានសមាជិក ៥ រូប កថាខណ្ឌ ២០១។

**៣.៧** កំហុសអង្គហេតុ៖ ការភ្លេចគិតថានៅឆ្នាំ ១៩៥៥-១៩៦០ បក្សបានបាត់បង់សណ្ដាប់ធ្នាប់ ហើយស្ទើរតែរលាយបាត់រូប កថាខណ្ឌ ២០១-២០២។

**៣.៨** កំហុសអង្គហេតុ៖ គោលបំណងរបស់បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ កថាខណ្ឌ ២០២។

**៣.៩** កំហុសអង្គហេតុ៖ សេចក្ដីសម្រេចរបស់មហាសន្និបាតនាឆ្នាំ១៩៦០ ក្នុងការតស៊ូនយោបាយ និងប្រដាប់អាវុធ កថាខណ្ឌ ២០៤។

**៣.១០** កំហុសអង្គហេតុ៖ ការបញ្ជាក់ឡើងវិញនៅឆ្នាំ ១៩៦៣ នូវវិធីសាស្ត្រនៃការប្រើហិង្សានយោបាយ និងហិង្សាប្រដាប់អាវុធ កថាខណ្ឌ ២០៦។

**៣.១១** កំហុសអង្គហេតុ៖ ការបញ្ចូលហិង្សាបដិវត្តន៍ទៅក្នុងមាគ៌ារបស់បក្ស ដោយគណៈកម្មាធិការមជ្ឈិមនៅខែមករា ឆ្នាំ១៩៦៥ កថាខណ្ឌ ២០៨។

**៣.១២** កំហុសអង្គហេតុ៖ ខែកញ្ញា ឆ្នាំ១៩៦៦ សេចក្ដីសម្រេចបង្គាប់ឱ្យភូមិភាគនីមួយៗត្រៀមរៀបចំការតស៊ូប្រដាប់អាវុធ កថាខណ្ឌ ២០៩។

**៣.១៣** កំហុសអង្គហេតុ៖ នួន ជា បាននាំ ខៀវ សំផន ហ៊ូ នឹម និង ហ៊ូ យន់ ទៅក្នុងព្រៃម៉ាគី កថាខណ្ឌ ២១១។

**៣.១៤** កំហុសអង្គហេតុ៖ ការអំពាវនាវចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ របស់សម្ដេចព្រះ នរោត្ដម សីហនុ ដែលត្រូវបានកែសម្រួល កថាខណ្ឌ ២១៨។

**៣.១៥** កំហុសអង្គហេតុ៖ លិខិតគាំទ្រចំពោះរណសិរ្សរួបរួមជាតិកម្ពុជា ក្នុងនាម "ខ្មោចទាំងបី" កថាខណ្ឌ ២១៩។

**៣.១៦** កំហុសអង្គហេតុ៖ តួនាទីជាអ្នកទំនាក់ទំនងរបស់ ខៀវ សំផន ជាមួយសម្ដេចព្រះ នរោត្ដម សីហនុ កថាខណ្ឌ ២២០។

**៣.១៧** កំហុសអង្គហេតុ៖ តួនាទី និងវិភាគទានរបស់ សម្ដេចព្រះ នរោត្ដម សីហនុ នៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា កថាខណ្ឌ ២២២។

**៣.១៨** កំហុសអង្គហេតុ៖ មហាសន្និបាតនាឆ្នាំ១៩៧១ និងសេចក្ដីសម្រេចថា វៀតណាមគឺជា "សត្រូវស្រួចស្រាវ" យូរអង្វែង កថាខណ្ឌ ២២៦។

**៣.១៩** កំហុសអង្គហេតុ៖ ការប្រជុំគណៈកម្មាធិការមជ្ឈិម នៅក្នុងខែឧសភា ឆ្នាំ១៩៧២ កថាខណ្ឌ ២២៧។

**៣.២០** កំហុសអង្គហេតុ៖ វត្តមានវៀតណាមនៅកម្ពុជា ក្រោយពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ក្នុងខែមករា ឆ្នាំ១៩៧៣ កថាខណ្ឌ ២២៨។

**៣.២១** កំហុសអង្គហេតុ៖ ប្រតិកម្មរបស់ខ្មែរក្រហម ក្រោយពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស នាខែមករា ឆ្នាំ១៩៧៣ កថាខណ្ឌ ២២៨។

**៣.២២** កំហុសអង្គហេតុ៖ ការទាញយកផលប្រយោជន៍របស់ ប.ក.ក. ពីស្ថានការណ៍នៃការទម្លាក់គ្រាប់បែក កថាខណ្ឌ ២២៩។

**៣.២៣** កំហុសអង្គហេតុ៖ ខ្មែរក្រហមអស់រៀតណាមរារាំង និងការផ្តោតការប្រយុទ្ធលើសាធារណរដ្ឋខ្មែរ កថាខណ្ឌ ២៣០។

**៣.២៤** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការប្រែក្រឡាស់ទាក់ទងនឹងវត្តមានរបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិម ប.ក.ក. នាខែមិថុនា ឆ្នាំ១៩៧៤ កថាខណ្ឌ ២៣០។

**៣.២៥** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ហ៊ូ យន់ ជាអ្នកមិនឯកភាព និងជាអ្នករងគ្រោះដោយការបោសសម្អាត ជាមួយនឹងសមាជិកគណៈកម្មាធិការមជ្ឈិមផ្សេងទៀត កថាខណ្ឌ ២៣០។

**៣.២៦** កំហុសអង្គហេតុ៖ ការប្រកាសផ្សព្វផ្សាយតាមវិទ្យុ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៤ ដែលត្រូវបានចាត់ទុកថាជាសេចក្តីប្រកាសរបស់ ខៀវ សំផន កថាខណ្ឌ ២៣១។

**៣.២៧** កំហុសអង្គហេតុ៖ សេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ ដែលត្រូវបានចាត់ទុកថាជាសេចក្តីប្រកាសរបស់ ខៀវ សំផន កថាខណ្ឌ ២៣១។

**៣.២៨** កំហុសអង្គហេតុ៖ ការអំពាវនាវរបស់ ខៀវ សំផន ក្នុងឋានៈជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា កថាខណ្ឌ ២៣១។

**៣.២៩** កំហុសអង្គហេតុ៖ សេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៧៥ កថា-ខណ្ឌ ២៣២។

**៣.៣០** កំហុសអង្គហេតុ៖ វត្តមាន ខៀវ សំផន នៅក្នុងកិច្ចប្រជុំមួយនាដើមខែមេសា ឆ្នាំ១៩៧៥ កថាខណ្ឌ ២៣៣។

## ការបង្កើតសហករណ៍ និងមន្ទីរសន្តិសុខ ក្នុងចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥

**៣.៣១** កំហុសអង្គហេតុ៖ សេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិម នាខែឧសភា ឆ្នាំ១៩៧២ ស្តីពីផ្សារសហករណ៍ និងការបញ្ឈប់ការប្រើប្រាស់រូបិយប័ណ្ណ និងការដាក់ឱ្យអនុវត្ត កថាខណ្ឌ ២៣៩។

**៣.៣២** កំហុសអង្គហេតុ៖ ហេតុផលរបស់ ខៀវ សំផន ដើម្បីពន្យល់ពីការបង្កើតសហករណ៍ កថាខណ្ឌ ២៤០។

៣.៣៣ កំហុសអង្គហេតុ៖ ខៀវ សំផន និងភាពចាំបាច់នៃការដាក់ឱ្យអនុវត្តកម្មវិធីសមូហភាពដោយបង្ខំ កថាខណ្ឌ ២៤១។

៣.៣៤ កំហុសអង្គហេតុ៖ សហករណ៍កម្រិតខ្ពស់ កថាខណ្ឌ ២៤២។

៣.៣៥ កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការដាក់ឱ្យដំណើរការសហករណ៍នៅក្នុងឆ្នាំ១៩៧៣ និងសមាគមផ្សេងៗ កថាខណ្ឌ ២៤៣។

៣.៣៦ កំហុសអង្គហេតុ៖ ដំណើរការរបស់មន្ទីរ ម-១៣ កថាខណ្ឌ ២៤៥-២៥០។

## ជនជាតិចាមនៅកម្ពុជា មុនឆ្នាំ១៩៧៥

៣.៣៧ កំហុសអង្គច្បាប់ និងអង្គហេតុ៖ ស្ថានភាពជនជាតិចាម មុនរបបកម្ពុជាប្រជាធិបតេយ្យ កថាខណ្ឌ ២៥១-២៥៦។

## ព្រះពុទ្ធសាសនានៅកម្ពុជា មុនឆ្នាំ១៩៧៥

៣.៣៨ កំហុសអង្គច្បាប់៖ ការស្នើសុំឱ្យពិនិត្យលើការប្រព្រឹត្តលើព្រះសង្ឃ មុនឆ្នាំ១៩៧៥ ដើម្បីបង្ហាញឱ្យឃើញពីលំនាំនៃការប្រព្រឹត្ត កថាខណ្ឌ ២៥៧-២៦៤។

៣.៣៩ កំហុសអង្គហេតុ៖ ព្រះសង្ឃពុទ្ធសាសនាត្រូវបានផ្សឹក ហើយពេលខ្លះត្រូវគំរាមសម្លាប់ ចាប់ពីឆ្នាំ១៩៧៣ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កថាខណ្ឌ ២៦៤។

## ការរៀបអាពាហ៍ពិពាហ៍នៅកម្ពុជា មុនឆ្នាំ១៩៧៥

៣.៤០ កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការរៀបអាពាហ៍ពិពាហ៍ដោយការផ្សំផ្គុំ និងការទុកចិត្តគ្នាទៅវិញទៅមករវាងឪពុកម្ដាយ និងកូនៗ កថាខណ្ឌ ២៦៦-២៦៧។

៣.៤១ កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការបំភ្លៃការងាររបស់អ្នកជំនាញ កថាខណ្ឌ ២៦៧។

៣.៤២ កំហុសអង្គហេតុ៖ តួនាទីសំខាន់របស់ព្រះសង្ឃក្នុងពិធីរៀបអាពាហ៍ពិពាហ៍ កថាខណ្ឌ ២៧១។

៣.៤៣ កំហុសអង្គហេតុ៖ វិធានការតម្រូវមួយចំនួន ដើម្បីរឹតត្បិតពិធីរៀបអាពាហ៍ពិពាហ៍ ចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ កថាខណ្ឌ ២៧៣។

៣.៤៤ កំហុសអង្គហេតុ៖ អាពាហ៍ពិពាហ៍មុនឆ្នាំ១៩៧៥ រៀបចំដោយអង្គការ កថាខណ្ឌ ២៧៣។

## និន្នាការទូទៅ៖ រយៈពេលចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩

២០. នៅក្នុង**ផ្នែកទី ៤** នៃសាលក្រមជាលាយល័ក្ខណ៍អក្សរ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តជាអាទិ៍នូវកំហុសដូចខាងក្រោម៖

### និន្នាការអង្គហេតុ (ក្នុងនោះមាន ប្រភេទនៃជម្លោះប្រដាប់អាវុធ)

**៤.១** កំហុសអង្គច្បាប់ និងអង្គហេតុ៖ មូលហេតុនៃការផ្លាស់ទីលំនៅប្រជាជន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កថាខណ្ឌ ២៧៨។

**៤.២** កំហុសអង្គច្បាប់ និងអង្គហេតុ៖ គោលបំណងនៃការបង្ខំឱ្យរៀបការ កថាខណ្ឌ ២៧៩។

**៤.៣** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ទស្សនាទានសម្ធហាភាពនិយមរបស់ ប.ក.ក. លើសង្គម កថាខណ្ឌ ២៧៩។

**៤.៤** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការដាក់ឱ្យអនុវត្តជាប្រព័ន្ធទូទៅនូវការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈពេញផ្ទៃប្រទេស តាមរយៈបណ្តាញរដ្ឋបាលរបស់ ប.ក.ក. កថាខណ្ឌ ២៧៩។

**៤.៥** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការប្រឈមមុខដាក់គ្នារវាងខ្មែរក្រហម និងវៀតណាម នៅក្រោយខែមេសា ឆ្នាំ១៩៧៥ កថាខណ្ឌ ២៨២-២៨៧។

**៤.៦** កំហុសអង្គហេតុ៖ ឡុង សាត ជាសាក្សីបានឃើញផ្ទាល់ភ្នែកនូវការវាយប្រហារនៅបន្ទាយ ២៧ កថាខណ្ឌ ២៨៨, ២៩២។

**៤.៧** កំហុសអង្គច្បាប់ និងអង្គហេតុ៖ សន្ទរកថា ប៉ុល ពត ក្នុងខែមេសា ឆ្នាំ១៩៧៨ (ឯកសារ E3/4604) កថាខណ្ឌ ២៩០។

**៤.៨** កំហុសអង្គហេតុ៖ សារប្រកាសតាមវិទ្យុរបស់ ខៀវ សំផន អំពាវនាវឱ្យទាហានប្រុងជើងការនៅចំពោះមុខសត្រូវ កថាខណ្ឌ ២៩០។

**៤.៩** កំហុសអង្គហេតុ៖ សំណើរបស់វៀតណាម សុំចរចាបញ្ហាព្រំដែនសាជាថ្មី ក្នុងឆ្នាំ១៩៧៨ តែសំណើនេះត្រូវបានបដិសេធ កថាខណ្ឌ ២៩១។

**៤.១០** កំហុសអង្គហេតុ៖ ប៉ុល ពត និងការប៉ុនប៉ងធ្វើរដ្ឋប្រហាររបស់ សោ ភឹម កថាខណ្ឌ ២៩២-២៩៣។

**៩.១១** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការវិភាគបែបដាក់បន្ទុកលើរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ កថាខណ្ឌ ២៩៤។

**៩.១២** កំហុសអង្គច្បាប់ និងអង្គហេតុ៖ អត្ថិភាពនៃគោលនយោបាយស្តីពីការប្រព្រឹត្តលើខ្មាំងជាក់លាក់ កថាខណ្ឌ ២៩៥។

**៩.១៣** កំហុសអង្គច្បាប់ និងអង្គហេតុ៖ សេចក្តីសន្និដ្ឋានលើអត្ថិភាពនៃការវាយប្រហារជាទូទៅលើជនស៊ីវិល កថាខណ្ឌ ២៩៦។

**៩.១៤** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការវាយតម្លៃលើចំនួនជនរងគ្រោះ កថាខណ្ឌ ២៩៦-២៩៧។

## លក្ខខណ្ឌទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

**៩.១៥** កំហុសអង្គច្បាប់៖ លក្ខខណ្ឌទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងគោលការណ៍នីត្យានុកូលភាព កថាខណ្ឌ ៣០០។

**៩.១៦** កំហុសអង្គច្បាប់៖ និយមន័យលក្ខខណ្ឌទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ កថាខណ្ឌ ៣០១-៣១៦។

**៩.១៧** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ប.ក.ក. បានបើកការវាយប្រហារជាទូទៅ និងជាប្រព័ន្ធមកលើប្រជាជន ក្នុងបំណងអនុវត្តគោលនយោបាយរបស់ខ្លួន កថាខណ្ឌ ៣១៧-៣១៨។

**៩.១៨** កំហុសអង្គច្បាប់៖ ការវាយប្រហារជាទូទៅ និងជាប្រព័ន្ធទៅលើប្រជាជនស៊ីវិល ក៏អាចជាការរើសអើងផងដែរ កថាខណ្ឌ ៣១៩-៣២០។

**៩.១៩** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការកំណត់លក្ខណៈនៃផែនការរួម និងមធ្យោបាយដើម្បីឈានទៅសម្រេចឱ្យបាន កថាខណ្ឌ ៣១៩។

**៩.២០** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការជ្រើសរើសយកការធ្វើបាប ឬការប្រើហិង្សា ចំពោះបុគ្គលគ្រប់រូបដែលត្រូវបានចាត់ទុកថាប្រឆាំងនឹងបដិវត្តន៍ និងប្រព័ន្ធសមូហភាព កថាខណ្ឌ ៣១៩។

**៩.២១** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការវាយប្រហារក្រោមរូបភាពជាការប្រព្រឹត្តជាក់លាក់ប្រឆាំងនឹងក្រុមជាក់លាក់ផ្សេងៗ ដោយមូលហេតុជាតិសាសន៍ ជាតិពន្ធុ ពូជសាសន៍ និងសាសនា កថាខណ្ឌ ៣២០។

**៩.២២** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការរំលោភលើការស្នើសុំឱ្យជំនុំជម្រះ ទាក់ទងនឹងការប្រព្រឹត្តលើពុទ្ធសាសនិក កថាខណ្ឌ ៣២០។

**៤.២៣** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការវាយប្រហារជាទូទៅ និងជាប្រព័ន្ធ ក្រោមទម្រង់ជាការប្រព្រឹត្ត លើជនជាតិចាម ដោយមូលហេតុជាតិពន្ធុ និងសាសនា និងលើជនជាតិវៀតណាម ដោយមូលហេតុជាតិពន្ធុ សញ្ជាតិ និងពូជសាសន៍ កថាខណ្ឌ ៣២០។

**៤.២៤** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ចំណងទាក់ទងផ្ទាល់រវាងចារីនៃការវាយប្រហារដែលរងការចោទប្រកាន់ ជាមួយ ខៀវ សំផន កថាខណ្ឌ ៣២១។

**៤.២៥** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការកំណត់លក្ខណៈនៃផែនការរួម និងមធ្យោបាយដើម្បីឈានទៅសម្រេចឱ្យបាន កថាខណ្ឌ ៣២១។

**៤.២៦** កំហុសអង្គច្បាប់ និងអង្គហេតុ៖ តួនាទីសំខាន់របស់ ខៀវ សំផន នៅក្នុងការរៀបចំបង្កើត/អនុវត្តគោលនយោបាយ កថាខណ្ឌ ៣២១

**៤.២៧** កំហុសអង្គច្បាប់ និងអង្គហេតុ៖ រឿងរ៉ាវដែល ខៀវ សំផន បានដឹងនៅសម័យកាលដែលអង្គហេតុកើតឡើង កថាខណ្ឌ ៣២២-៣២៣។

**៤.២៨** កំហុសអង្គច្បាប់ និងអង្គហេតុ៖ តួនាទី មុខងាររបស់ ខៀវ សំផន និងការចូលរួមក្នុងការរៀបចំបង្កើតគោលនយោបាយ កថាខណ្ឌ ៣២២-៣២៣។

**៤.២៩** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការវាយប្រហារជាទូទៅលើប្រជាជន គឺជាផ្នែកមួយនៃគោលនយោបាយ កថាខណ្ឌ ៣២២-៣២៣។

***លក្ខខណ្ឌទូទៅនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩***

៤.៣០ កំហុសអង្គច្បាប់៖ លក្ខខណ្ឌទូទៅនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងគោលការណ៍នីត្យានុកូលភាព កថាខណ្ឌ ៣២៥-៣២៦។

**៤.៣១** កំហុសអង្គច្បាប់៖ និយមន័យនៃលក្ខខណ្ឌទូទៅនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ កថាខណ្ឌ ៣២៧-៣៣៥។

**៤.៣២** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ខៀវ សំផន មេដឹកនាំជាន់ខ្ពស់ មានចំណងទាក់ទងជាមួយមន្ទីរសន្តិសុខ ស-២១ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កថាខណ្ឌ ៣៣៨-៣៤០។

**៤.៣៣** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ខៀវ សំផន បានជួបឌុច ក្នុងរយៈពេលខ្លី នៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ កថាខណ្ឌ ៣៤០។

**៤.៣៤** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ខៀវ សំផន បានដឹងពីឋានៈរបស់ជនរងគ្រោះដែលទទួលបានការការពារនៅមន្ទីរសន្តិសុខ ស-២១ កថាខណ្ឌ ៣៤០។

## រចនាសម្ព័ន្ធរដ្ឋបាល

២១. នៅក្នុង**ផ្នែកទី ៥** នៃសាលក្រមជាលាយល័ក្ខណ៍អក្សរ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តជាអាទិ៍នូវកំហុសដូចខាងក្រោម៖

**៥.១** កំហុសអង្គហេតុ៖ ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធចាត់តាំងរបស់ ប.ក.ក. និងគោលការណ៍រក្សាការសម្ងាត់ កថាខណ្ឌ ៣៤២-៥៥៤។

**៥.២** កំហុសអង្គហេតុ៖ កាលបរិច្ឆេទនៃសន្និបាត ប.ក.ក. លើកទី៤ នាឆ្នាំ១៩៧៦ កថាខណ្ឌ ៣៤៣។

**៥.៣** កំហុសអង្គហេតុ៖ ការបញ្ជាក់យថាភាពលើលក្ខន្តិកៈ ឆ្នាំ១៩៧៦ កថាខណ្ឌ ៣៤៤។

**៥.៤** កំហុសអង្គហេតុ៖ ការចូលរួមក្នុងសន្និបាតឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៨ កថាខណ្ឌ ៣៤៥។

**៥.៥** កំហុសអង្គច្បាប់ និងអង្គហេតុ៖ យថាភាព និងតម្លៃជាភ័ស្តុតាងនៃកំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន ២៣ ក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៤៧-៣៥០។

**៥.៦** កំហុសអង្គច្បាប់ និងអង្គហេតុ៖ តម្លៃនៃសម្រង់កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលត្រូវបានបង្ហាញនៅចំពោះមុខតុលាការប្រជាជនបដិវត្តន៍ ឆ្នាំ១៩៧៩ កថាខណ្ឌ ៣៥១។

**៥.៧** កំហុសអង្គច្បាប់ និងកំហុសនៃការប្រើឆន្ទានុសិទ្ធិ៖ ការទទួលបាន និងការទទួលយកឯកសារចំនួន ១៣ ដែលបានមកពីលោក GOSCHA កថាខណ្ឌ ៣៥២-៣៥៤។

**៥.៨** កំហុសអង្គច្បាប់ និងអង្គហេតុ៖ តម្លៃផ្តល់ឱ្យឯកសារទាំង ១៣ របស់លោក GOSCHA កថាខណ្ឌ ៣៥២-៣៥៤។

**៥.៩** កំហុសអង្គហេតុ៖ កាលបរិច្ឆេទនៃការទទួលយក ខៀវ សំផន ធ្វើជាសមាជិកពេញសិទ្ធិ នៅក្នុងគណៈកម្មាធិការមជ្ឈិម កថាខណ្ឌ ៣៥៥។

**៥.១០** កំហុសអង្គហេតុ៖ សមាសភាពគណៈកម្មាធិការមជ្ឈិម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កថាខណ្ឌ ៣៥៦។

**៥.១១** កំហុសអង្គច្បាប់ និងអង្គហេតុ៖ គណៈកម្មាធិការមជ្ឈិមមានអំណាចចាត់តាំងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងសមាជិកផ្សេងៗទៀត កថាខណ្ឌ ៣៥៧។

**៥.១២** កំហុសអង្គហេតុ៖ ចំនួននៃការចូលរួមរបស់ ខៀវ សំផន ក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ កថាខណ្ឌ ៣៥៧។

**៥.១៣** កំហុសអង្គច្បាប់ និងអង្គហេតុ៖ សមាជិកគណៈកម្មាធិការមជ្ឈិម/គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលត្រូវបានបោសសម្អាត ក្រោយពីត្រូវបានឆ្លើយដាក់នៅក្នុងចម្លើយសារភាព កថាខណ្ឌ ៣៥៨។

**៥.១៤** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការបង្កើតគណៈកម្មាធិការដឹកនាំ នៅក្នុងកងកម្លាំងប្រដាប់អាវុធ ចំណុះឱ្យប្រជាធិបតេយ្យប្រមូលផ្ដុំ កថាខណ្ឌ ៣៥៩។

**៥.១៥** កំហុសអង្គហេតុ៖ ការប្រើប្រាស់ពាក្យ "មជ្ឈិមបក្ស" កថាខណ្ឌ ៣៦០-៣៦១។

**៥.១៦** កំហុសអង្គហេតុ៖ ការប្រើប្រាស់លេខកូដ "៨៧០" កថាខណ្ឌ ៣៦២។

**៥.១៧** កំហុសអង្គហេតុ៖ តួនាទី និងមុខងាររបស់មន្ទីរ ៨៧០ កថាខណ្ឌ ៣៦២-៣៦៥។

**៥.១៨** កំហុសអង្គហេតុ៖ សមាសភាព និងដំណើរការរបស់មន្ទីរ ៨៧០ កថាខណ្ឌ ៣៦៤-៣៦៥។

**៥.១៩** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការចាប់ខ្លួនសមាជិកបក្សដែលត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព កថាខណ្ឌ ៣៧៥។

**៥.២០** កំហុសអង្គច្បាប់៖ ការស្នើសុំឱ្យជំនុំជម្រះដោយពុំត្រឹមត្រូវលើអង្គហេតុទាក់ទងនឹងការបោសសម្អាត កថាខណ្ឌ ៣៧៦-៣៨២, ៣៨៥-៣៨៧, ៤០៤-៤០៥។

**៥.២១** កំហុសអង្គហេតុ៖ ការប្រើពាក្យ "អង្គការ" កថាខណ្ឌ ៣៨៨-៣៨៩។

**៥.២២** កំហុសអង្គហេតុ៖ ប្រជាធិបតេយ្យប្រមូលផ្ដុំ និងការធ្វើសេចក្ដីសម្រេច កថាខណ្ឌ ៣៩០-៣៩៧, ៣៩៩។

**៥.២៣** កំហុសអង្គហេតុ៖ ការប្រៀបធៀបលក្ខន្តិកៈបក្ស ឆ្នាំ១៩៦០ ១៩៧១ និង ១៩៧៦ កថាខណ្ឌ ៣៩៨។

**៥.២៤** កំហុសអង្គហេតុ៖ ការណែនាំបេក្ខជន ដោយសមាជិកពេញសិទ្ធិរបស់បក្ស កថាខណ្ឌ ៣៩៩-៤០០។

**៥.២៥** កំហុសអង្គហេតុ៖ សេចក្ដីសម្រេចរបស់គណៈកម្មាធិការមជ្ឈិម នៅពាក់កណ្ដាលឆ្នាំ១៩៧៤ ស្ដីពីការឈប់ទទួលយកសមាជិកចូលបក្ស កថាខណ្ឌ ៤០២។

**៥.២៦** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ចំនួនសមាជិកបក្ស និងការបោសសម្អាត កថាខណ្ឌ ៤០១-៤០៦។

**៥.២៧** កំហុសអង្គហេតុ៖ ការចាត់តាំងរបស់គណៈកម្មាធិការមជ្ឈិម នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ក្នុងនោះ ខៀវ សំផន ឱ្យទៅក្នុងគណៈប្រធានរដ្ឋ កថាខណ្ឌ ៤១៤។

**៥.២៨** កំហុសអង្គហេតុ៖ មតិយោល់របស់គណៈកម្មាធិការមជ្ឈិមថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យត្រូវតែជាអង្គការរបស់បក្សសុទ្ធសាធ កថាខណ្ឌ ៤១៦។

**៥.២៩** កំហុសអង្គហេតុ៖ ការបង្កើតគណៈកម្មាធិការក្នុងវិស័យសេដ្ឋកិច្ច និងស្ថិតក្រោមការគ្រប់គ្រងរបស់ វន វេត និង ខៀវ សំផន កថាខណ្ឌ ៤២១។

**៥.៣០** កំហុសអង្គហេតុ៖ ខៀវ សំផន បានដឹងយ៉ាងលម្អិតអំពីបញ្ហាសេដ្ឋកិច្ចកម្ពុជាប្រជាធិបតេយ្យ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការទាំងនោះ ចាប់ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨ កថាខណ្ឌ ៤២១។

**៥.៣១** កំហុសអង្គហេតុ៖ ការទទួលបានរបាយការណ៍ដោយ ខៀវ សំផន ក្រោយពី វន វ៉េត ត្រូវចាប់ខ្លួន កថាខណ្ឌ ៤២១។

**៥.៣២** កំហុសអង្គហេតុ៖ ក្រុមហ៊ុន FORTRA និងក្រុមហ៊ុន Ren Fung ក្រោមការគ្រប់គ្រងរបស់ គណៈកម្មាធិការពាណិជ្ជកម្ម ត្រូវរាយការណ៍ទៅ ខៀវ សំផន កថាខណ្ឌ ៤២២។

**៥.៣៣** កំហុសអង្គហេតុ៖ ការប្រកាសស្ដីពីការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា និងកងពលភូមិភាគមួយចំនួនឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការមជ្ឈិម កថាខណ្ឌ ៤២៥។

**៥.៣៤** កំហុសអង្គហេតុ៖ វត្តមាន នួន ជា និង ខៀវ សំផន ក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ កថាខណ្ឌ ៤២៥។

**៥.៣៥** កំហុសអង្គហេតុ៖ ការប្រើប្រាស់ពាក្យ “កងពលមជ្ឈិម” កថាខណ្ឌ ៤២៥។

**៥.៣៦** កំហុសអង្គហេតុ៖ សេនាធិការកងទ័ពបដិវត្តន៍កម្ពុជា ដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់គណៈ-កម្មាធិការមជ្ឈិម និងគណៈកម្មាធិការយោធា កថាខណ្ឌ ៤២៧។

**៥.៣៧** កំហុសអង្គហេតុ៖ មន្ទីរសន្តិសុខ ស-២១ ស្ថិតក្រោមសេនាធិការតែលើបញ្ហាភស្តុភារប៉ុណ្ណោះ កថាខណ្ឌ ៤៥០។

**៥.៣៨** កំហុសអង្គហេតុ៖ អត្ថិភាពនៃកងពិសេសនៅថ្នាក់ឃុំ កថាខណ្ឌ ៤៥៤។

## <u>ប្រព័ន្ធទំនាក់ទំនង</u>

២២. នៅក្នុង**ផ្នែកទី ៦** នៃសាលក្រមជាលាយល័ក្ខណ៍អក្សរ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តជាអាទិ៍នូវកំហុសដូចខាងក្រោម៖

**៦.១** កំហុសអង្គច្បាប់ និងអង្គហេតុ៖ តម្លៃជាភស្តុតាងនៃលិខិតឆ្លងឆ្លើយផ្លូវការ ក្រោមទម្រង់ផ្សេងៗគ្នា កថាខណ្ឌ ៤៥៥។

**៦.២** កំហុសអង្គហេតុ៖ ប្រព័ន្ធទូរលេខត្រូវបានរក្សាទុករហូតដល់វៀតណាមចូលនៅឆ្នាំ ១៩៧៩ កថាខណ្ឌ ៤៥៦។

**៦.៣** កំហុសអង្គហេតុ៖ ដំណើរការនៃប្រព័ន្ធទំនាក់ទំនងតាមទូរលេខ កថាខណ្ឌ ៤៥៧-៤៥៩។

៦.៤ កំហុសអង្គហេតុ៖ សំបុត្រចូល ផ្ញើជូន "មជ្ឈិមបក្ស" តាមរយៈមន្ទីរ ក-៧ កថាខណ្ឌ ៤៦០។

៦.៥ កំហុសអង្គហេតុ៖ វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជានៅទីក្រុងហាណូយ មានបុគ្គលិកភាគច្រើនជាសមាជិក ប.ក.ក. កថាខណ្ឌ ៤៦៤។

៦.៦ កំហុសអង្គហេតុ៖ ការផ្សាយខ្សែអាត់សំឡេងសុន្ទរកថា និងបទសម្ភាសន៍មេដឹកនាំ កថាខណ្ឌ ៤៦៥។

៦.៧ កំហុសអង្គហេតុ៖ ព័ត៌មានសម្រាប់ចាក់ផ្សាយ ផ្ដោតលើប្រធានបទផ្សេងៗគ្នា កថាខណ្ឌ ៤៦៦។

៦.៨ កំហុសអង្គហេតុ៖ កម្មវិធីផ្សាយខ្សែអាត់សំឡេងសារភាពរបស់ទាហានវៀតណាមដែលត្រូវបានចាប់ខ្លួន កថាខណ្ឌ ៤៦៦។

៦.៩ កំហុសអង្គហេតុ៖ កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ក្នុងខែមីនា ឆ្នាំ១៩៧៦ និងភាពចាំបាច់នៃព័ត៌មានស្ដីពីការបោះឆ្នោត កថាខណ្ឌ ៤៦៦។

៦.១០ កំហុសអង្គហេតុ៖ សេរីភាពទទួលបានព័ត៌មានតាមរយៈវិទ្យុ កថាខណ្ឌ ៤៦៨។

៦.១១ កំហុសអង្គហេតុ៖ ការប្រៀបធៀបរវាងសុន្ទរកថានៅក្នុងសេវាផ្សព្វផ្សាយព័ត៌មានទៅបរទេសជាមួយនឹងសុន្ទរកថានៅក្នុងអត្ថបទបោះពុម្ពផ្សាយរបស់កម្ពុជាប្រជាធិបតេយ្យ កថាខណ្ឌ ៤៧០។

៦.១២ កំហុសអង្គហេតុ៖ សេវាផ្សព្វផ្សាយព័ត៌មានទៅបរទេស និងសេចក្ដីរាយការណ៍សង្ខេបសេវាកម្មផ្សាយសំឡេងនៅទូទាំងពិភពលោក គឺជាភ័ស្តុតាងសំខាន់ កថាខណ្ឌ ៤៧០-៤៧១។

៦.១៣ កំហុសអង្គហេតុ៖ ការចែកចាយទស្សនាវដ្ដីទង់បដិវត្ត កថាខណ្ឌ ៤៧៥។

៦.១៤ កំហុសអង្គហេតុ៖ ប.ក.ក. គិតថាវាជាការសំខាន់ដែលសមាជិកខ្លួនត្រូវអានទស្សនាវដ្ដីទង់បដិវត្ត កថាខណ្ឌ ៤៧៧។

៦.១៥ កំហុសអង្គច្បាប់៖ យថាភាពនៃទស្សនាវដ្ដីទង់បដិវត្ត និងទស្សនាវដ្ដី យុវជន និងយុវនារីបដិវត្ត ដែលត្រូវបានដាក់ចូលក្នុងសំណុំរឿង កថាខណ្ឌ ៤៧៨។

៦.១៦ កំហុសអង្គហេតុ៖ លក្ខខណ្ឌពាក់ព័ន្ធនឹងការផ្ទៀងផ្ទាត់លើទស្សនាវដ្ដីទទួលយកដោយអង្គជំនុំជម្រះ កថាខណ្ឌ ៤៧៨។

៦.១៧ កំហុសអង្គហេតុ៖ ទំនាក់ទំនងខ្សែទទឹងនៅក្នុង "មជ្ឈិមបក្ស" កថាខណ្ឌ ៤៨៣។

៦.១៨ កំហុសអង្គហេតុ៖ កំណត់ហេតុប្រជុំដែលត្រូវបានរក្សាទុក បង្ហាញថាគណៈកម្មាធិការមជ្ឈិម និង គណៈកម្មាធិការអចិន្ត្រៃយ៍ បានប្រជុំជាទៀងទាត់ កថាខណ្ឌ ៤៨៤។

៦.១៩ កំហុសអង្គហេតុ៖ ការប្រជុំរបស់ ប៉ុល ពត នួន ជា និង ខៀវ សំផន ទល់មុខគ្នា ឬច្រើនគ្នា នៅមន្ទីរ ក-១ និងនៅមន្ទីរ ក-៣ កថាខណ្ឌ ៤៨៤។

៦.២០ កំហុសអង្គហេតុ៖ មន្ទីររបស់ "គណៈមជ្ឈិម" និងការទំនាក់ទំនងតាមទូរសព្ទ កថាខណ្ឌ ៤៨៥។

៦.២១ កំហុសអង្គហេតុ៖ ទូរលេខពីថ្នាក់ក្រោម ផ្ញើទៅ "មជ្ឈិមបក្ស" នៅមន្ទីរ ក-១ កថាខណ្ឌ ៤៨៦។

**៦.២២** កំហុសអង្គហេតុ៖ ការលាយច្របល់គ្នារវាង "មជ្ឈិមបក្ស" គណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គភាពផ្សេងៗទៀតរបស់ ប.ក.ក. នៅភ្នំពេញ កថាខណ្ឌ ៤៨៧-៤៩៣។

**៦.២៣** កំហុសអង្គហេតុ៖ របាយការណ៍ផ្ទាល់ពីភូមិភាគ និងតំបន់ស្វយ័ត ផ្ញើទៅ "មជ្ឈិមបក្ស" កថាខណ្ឌ ៤៨៧។

**៦.២៤** កំហុសអង្គហេតុ៖ របាយការណ៍សំយោគរបស់ភូមិភាគ និងតំបន់ស្វយ័ត សម្រាប់ "មជ្ឈិមបក្ស" កថាខណ្ឌ ៤៨៩។

**៦.២៥** កំហុសអង្គហេតុ៖ ការផ្ញើរបាយការណ៍ចេញជាទៀងទាត់ និងពេលខ្លះ ផ្ញើជាប្រចាំថ្ងៃ កថាខណ្ឌ ៤៨៩។

**៦.២៦** កំហុសអង្គហេតុ៖ តំណាងភូមិភាគ និងតំណាងតំបន់ស្វយ័ត រាយការណ៍ដោយផ្ទាល់ទៅ "មជ្ឈិមបក្ស" កថាខណ្ឌ ៤៨៩។

**៦.២៧** កំហុសអង្គហេតុ៖ របាយការណ៍របស់ភូមិភាគ និងតំបន់ ផ្ញើទៅ "មជ្ឈិមបក្ស" សំណើសុំការណែនាំលើប្រធានបទផ្សេងៗ ឬស្នើសុំជំនួយសម្ភារ កថាខណ្ឌ ៤៩១។

**៦.២៨** កំហុសអង្គហេតុ៖ ទូរលេខប្រើដោយ "មជ្ឈិមបក្ស" ដើម្បីបញ្ជូនសេចក្តីណែនាំ កថាខណ្ឌ ៤៩៣។

**៦.២៩** កំហុសអង្គហេតុ៖ ការផ្ញើទូរលេខជាទៀងទាត់របស់ ខៀវ សំផន កថាខណ្ឌ ៤៩៣។

**៦.៣០** កំហុសអង្គហេតុ៖ អ្នកទទួលខុសត្រូវភូមិភាគ និងតំបន់ស្វយ័ត បានទទួលសំបុត្រពីមន្ទីរ ៨៧០ និងពីមេដឹកនាំ ប.ក.ក. ជាក់លាក់មួយចំនួន ក្នុងនោះមាន ខៀវ សំផន ផងដែរ កថាខណ្ឌ ៤៩៣។

**៦.៣១** កំហុសអង្គហេតុ៖ ការបញ្ជូនរបាយការណ៍ពីថ្នាក់ស្រុកទៅឱ្យ"មជ្ឈិមបក្ស" កថាខណ្ឌ ៤៩៦។

**៦.៣២** កំហុសអង្គហេតុ៖ របាយការណ៍ស្រុកផ្ញើទៅតំបន់ ទាក់ទងនឹងបញ្ហាផ្សេងៗ កថាខណ្ឌ ៤៩៧។

**៦.៣៣** កំហុសអង្គហេតុ៖ ការបញ្ជូនសេចក្តីណែនាំរបស់"មជ្ឈិមបក្ស" ទៅរហូតដល់ថ្នាក់ស្រុក កថាខណ្ឌ ៤៩៩។

**៦.៣៤** កំហុសអង្គហេតុ៖ អ្នកទទួលខុសត្រូវថ្នាក់ស្រុក និងថ្នាក់ឃុំ ឬ សហករណ៍ បានជួបគ្នាផ្ទាល់ជាញឹកញាប់ ដើម្បីផ្លាស់ប្តូរព័ត៌មានគ្នា ឬផ្សព្វផ្សាយបទបញ្ជាផ្សេងៗ កថាខណ្ឌ ៥០០។

**៦.៣៥** កំហុសអង្គហេតុ៖ ថ្នាក់ក្រោមរបស់ស្រុក បញ្ជូនសំណើ និងរបាយការណ៍ពាក់ព័ន្ធនឹងបញ្ហាផ្សេងៗទៅថ្នាក់ស្រុក កថាខណ្ឌ ៥០១។

**៦.៣៦** កំហុសអង្គហេតុ៖ ទស្សនកិច្ចរបស់គណៈប្រតិភូពាណិជ្ជកម្មបរទេស និងកិច្ចប្រជុំនៅក្រសួងពាណិជ្ជកម្ម កថាខណ្ឌ ៥០៥។

**៦.៣៧** កំហុសអង្គហេតុ៖ ការបញ្ជូនសារ និងរបាយការណ៍ជាលាយល័ក្ខណ៍អក្សរ ដែល សុន សេន ទទួលបានពីមេបញ្ជាការយោធា បន្តទៅឱ្យមេដឹកនាំ ប.ក.ក. ផ្សេងទៀត ក្នុងនោះមានទាំងសំណើសុំការណែនាំផងដែរ កថាខណ្ឌ ៥០៨។

**៦.៣៨** កំហុសអង្គហេតុ៖ សុន សេន ចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងបានរាយការណ៍ជូនអង្គប្រជុំ កថាខណ្ឌ ៥០៨។

**៦.៣៩** កំហុសអង្គហេតុ៖ ទំនាក់ទំនងរវាងសេនាធិការ ជាមួយកងពលធំ តាមរយៈទូរលេខ ឬទូរសព្ទ កថា-ខណ្ឌ ៥០៩។

**៦.៤០** កំហុសអង្គហេតុ៖ កងពលយោធាស្ថិតក្រោមការបញ្ជារបស់ "មជ្ឈិមបក្ស" កថាខណ្ឌ ៥០៩។

**៦.៤១** កំហុសអង្គហេតុ៖ ការប្រជុំ/ការប្រមូលផ្តុំកងទ័ព នៅភ្នំពេញ ដែលក្នុងនោះ ខៀវ សំផន បានចូលរួមខ្លះដែរ កថាខណ្ឌ ៥១០។

**៦.៤២** កំហុសអង្គហេតុ៖ កងពលបានរាយការណ៍បញ្ហាផ្សេងៗ ជាទៀងទាត់ទៅសេនាធិការ កថាខណ្ឌ ៥១១។

**<u>តួនាទី/មុខងាររបស់ ខៀវ សំផន</u>**

២៣. នៅក្នុង**ផ្នែកទី ៨** នៃសាលក្រមជាលាយល័ក្ខណ៍អក្សរ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តជាអាទិ៍នូវកំហុសដូចខាងក្រោម៖

## ព័ត៌មានផ្ទាល់ខ្លួន និងសម័យកាលមុនរបបកម្ពុជាប្រជាធិបតេយ្យ

### កុមារភាព យុវវ័យ និងការងារ

**៨.១** កំហុសអង្គហេតុ៖ សកម្មភាព និងការចូលរួមរបស់ ខៀវ សំផន នៅប្រទេសបារាំង កថាខណ្ឌ ៥៦៥-៥៦៦។

**៨.២** កំហុសអង្គហេតុ៖ និក្ខេបបទថ្នាក់បណ្ឌិតរបស់ ខៀវ សំផន និងការបង្ហាញជាមុននូវទិដ្ឋភាពមនោ-គមន៍វិជ្ជារបស់ ប.ក.ក. កថាខណ្ឌ ៥៦៧-៥៦៨។

**៨.៣** កំហុសអង្គហេតុ៖ កម្មវត្ថុ ខ្លឹមសារ និងការគាំទ្ររបស់កាសែត L'Observateur កថាខណ្ឌ ៥៦៩។

**៨.៤** កំហុសអង្គហេតុ៖ ការបំភ្លេចចោលនូវភ័ស្តុតាងដោះបន្ទុកនៅក្នុងអាជីពការងាររបស់ ខៀវ សំផន កថាខណ្ឌ ៥៦៩-៥៧១។

**សមាជិក ប.ក.ក.**

**៨.៥** កំហុសអង្គហេតុ៖ សកម្មភាពរបស់ ខៀវ សំផន នៅចន្លោះឆ្នាំ១៩៦៧ ដល់ឆ្នាំ១៩៧០ កថាខណ្ឌ ៥៧៣។

**៨.៦** កំហុសអង្គហេតុ៖ ផលប៉ះពាល់នៃការទទួលយក ខៀវ សំផន ឱ្យចូលក្នុងបក្ស ប.ក.ក. កថាខណ្ឌ ៥៧៣។

**៨.៧** កំហុសអង្គហេតុ៖ ការស្គាល់អនាគតសមាជិកសំខាន់ៗរបស់បក្ស កថាខណ្ឌ ៥៧៣។

**៨.៨** កំហុសអង្គហេតុ៖ កាលបរិច្ឆេទនៃការទទួលយក ខៀវ សំផន ធ្វើជាសមាជិកពេញសិទ្ធិនៅក្នុងគណៈកម្មាធិការមជ្ឈិម កថាខណ្ឌ ៥៧៤។

**ពីឆ្នាំ១៩៧០ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥**

**៨.៩** កំហុសអង្គហេតុ៖ សារគាំទ្រផ្ញើជូនរណសិរ្សរួបរួមជាតិកម្ពុជា ក្រោយរដ្ឋប្រហារ និងតួនាទីរបស់ ខៀវ សំផន កថាខណ្ឌ ៥៧៥។

**៨.១០** កំហុសអង្គហេតុ៖ តួនាទីសំខាន់ជាអ្នកទំនាក់ទំនងរវាង ប.ក.ក. និងសម្តេចព្រះ នរោត្តម សីហនុ កថាខណ្ឌ ៥៧៦។

**៨.១១** កំហុសអង្គហេតុ៖ តំណាងនៃចលនាតស៊ូដែលគ្រប់គ្រងដោយ ប.ក.ក. កថាខណ្ឌ ៥៧៧។

**៨.១២** កំហុសអង្គហេតុ៖ ការជួយដល់ការរៀបចំបង្កើតឯកសារឃោសនារបស់រណសិរ្សរួបរួមជាតិកម្ពុជា និងជួយដល់ការរៀបចំវគ្គបណ្តុះបណ្តាលនយោបាយ កថាខណ្ឌ ៥៧៨។

**៨.១៣** កំហុសអង្គហេតុ៖ បេសកកម្ម និងដំណើរទស្សនកិច្ចនៅទីជនបទ និងតំបន់រំដោះ កថាខណ្ឌ ៥៧៩។

**៨.១៤** កំហុសអង្គហេតុ៖ ការទទួលគណៈប្រតិភូរដ្ឋាភិបាលប្រជាជនបដិវត្ត នៃសាធារណរដ្ឋវៀតណាមខាងត្បូង កថាខណ្ឌ ៥៨០។

**៨.១៥** កំហុសអង្គហេតុ៖ ការតែងតាំងជាប្រធានសមាគមមិត្តភាពកម្ពុជា-វៀតណាម កថាខណ្ឌ ៥៨០។

**៨.១៦** កំហុសអង្គហេតុ៖ សេចក្តីប្រកាស សេចក្តីថ្លែងការណ៍ និងសុន្ទរកថារបស់ ខៀវ សំផន នៅឆ្នាំ ១៩៧៥-១៩៧៦ កថាខណ្ឌ ៥៨១។

**៨.១៧** កំហុសអង្គហេតុ៖ ការទៅនៅមន្ទីរ ប-៥ របស់ ខៀវ សំផន កថាខណ្ឌ ៥៨១។

**៨.១៨** កំហុសអង្គហេតុ៖ តួនាទីសំខាន់ក្នុងការទាក់ទាញការគាំទ្រ កថាខណ្ឌ ៥៨២។

**៨.១៩** កំហុសអង្គហេតុ៖ ការចូលរួមវិភាគទានដល់ការផ្តល់ និងពង្រឹងភាពស្របច្បាប់ដល់ចលនាតស៊ូគ្រប់គ្រងដោយ ប.ក.ក. កថាខណ្ឌ ៥៨២។

## ការចូលរួមប្រជុំគណៈកម្មាធិការមជ្ឈិម នាខែមិថុនា ឆ្នាំ១៩៧៤ និងកិច្ចប្រជុំថ្នាក់ដឹកនាំ នាខែមេសា ឆ្នាំ១៩៧៥

**៨.២០** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការចូលរួមរបស់ ខៀវ សំផន ក្នុងកិច្ចប្រជុំមួយនៅមន្ទីរ ប-៥ នាខែមេសា ឆ្នាំ១៩៧៥ កថាខណ្ឌ ៥៨៣-៥៨៨។

**៨.២១** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ការប្រែប្រួលឡាស់ទាក់ទងនឹងសំណុំរឿង ០០២/០១ ពាក់ព័ន្ធនឹងកិច្ចប្រជុំ នាខែមិថុនា ឆ្នាំ១៩៧៤ កថាខណ្ឌ ៥៨៣-៥៨៨។

## កន្លែងស្នាក់នៅ កន្លែងធ្វើការ និងទីតាំងធ្វើដំណើរក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ

**៨.២២** កំហុសអង្គហេតុ៖ កន្លែងស្នាក់នៅ និងទំនាក់ទំនងជិតស្និទ្ធជាមួយមេដឹកនាំមួយចំនួន កថាខណ្ឌ ៥៨៩, ៥២៦, ៥៣៤។

**៨.២៣** កំហុសអង្គហេតុ៖ កាធ្វើដំណើរនៅក្នុងប្រទេសកម្ពុជា ដើម្បីពិនិត្យមើលការដ្ឋានការងារ កថាខណ្ឌ ៥៩០។

## តួនាទីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ និងអគ្គមេបញ្ជាការ នៃកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា

**៨.២៤** កំហុសអង្គហេតុ៖ សមាជដែលមានការចូលរួមពី ខៀវ សំផន និងភាពស្របច្បាប់នៃកម្មវិធី ប.ក.ក. នៅលើឆាកអន្តរជាតិ កថាខណ្ឌ ៥៩៣។

## ប្រធានគណៈប្រធានរដ្ឋ

**៨.២៥** កំហុសអង្គហេតុ៖ ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ ដោយគណៈកម្មាធិការមជ្ឈិម នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ កថាខណ្ឌ ៥៩៦។

**៨.២៦** កំហុសអង្គហេតុ៖ សុន្ទរកថារបស់ ខៀវ សំផន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កថាខណ្ឌ ៥៩៨។

**៨.២៧** កំហុសអង្គហេតុ៖ ការផ្សព្វផ្សាយជាទូទៅនូវមាគ៌ារបស់ ប.ក.ក. កថាខណ្ឌ ៥៩៩។

## សមាជិកគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍

**៨.២៨** កំហុសអង្គហេតុ៖ កាលបរិច្ឆេទនៃការតែងតាំង ខៀវ សំផន ធ្វើជាសមាជិកពេញសិទ្ធិ នៃគណៈកម្មាធិការមជ្ឈិម កថាខណ្ឌ ៦០០។

**៨.២៩** កំហុសអង្គហេតុ៖ មុខងាររបស់គណៈកម្មាធិការមជ្ឈិម កថាខណ្ឌ ៦០០។

**៨.៣០** កំហុសអង្គហេតុ៖ ចំនួននៃការចូលរួមរបស់ ខៀវ សំផន ក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ កថាខណ្ឌ ៦០២។

**៨.៣១** កំហុសអង្គហេតុ៖ ការចូលរួមរបស់ ខៀវ សំផន ក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ កថាខណ្ឌ ៦០២។

**៨.៣២** កំហុសអង្គហេតុ៖ វត្តមានក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងការបានដឹងពីបញ្ហាដែលលើកយកមកពិភាក្សា កថាខណ្ឌ ៦០៣។

**៨.៣៣** កំហុសអង្គហេតុ៖ ស្ថិតក្នុងក្រុមតូចមួយរបស់សមាជិក ប.ក.ក. ដែលទទួលបានព័ត៌មានពេញលេញ កថាខណ្ឌ ៦០៤។

**៨.៣៤** កំហុសអង្គហេតុ៖ តួនាទីពិសេសនៅក្នុងបក្ស កថាខណ្ឌ ៦០៤។

## មុខងារបន្ទាប់បន្សំផ្សេងទៀត

**៨.៣៥** កំហុសអង្គច្បាប់ និងអង្គហេតុ៖ ខៀវ សំផន មានមុខងារផ្សេងទៀត ដែលមិនស្ថិតនៅក្នុងតួនាទីផ្លូវការរបស់គាត់ ឬដែលអង្គជំនុំជម្រះមិនអាចបញ្ចូលទៅក្នុងតួនាទីជាក់លាក់ណាមួយបាន កថាខណ្ឌ ៦០៥។

**៨.៣៦** កំហុសអង្គហេតុ៖ ខៀវ សំផន បានអមព្រះរាជដំណើរទស្សនកិច្ចរបស់សម្តេចព្រះ នរោត្តម សីហនុ ពិនិត្យមើលគម្រោងកសិកម្ម និងការដ្ឋានការងារនានា កថាខណ្ឌ ៦០៦។

**៨.៣៧** កំហុសអង្គហេតុ៖ ខៀវ សំផន បានចូលរួម/ឧទ្ទេសនាមវគ្គបណ្តុះបណ្តាលនយោបាយ នៅចន្លោះខែមេសា ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ កថាខណ្ឌ ៦០៧។

**៨.៣៨** កំហុសអង្គហេតុ៖ អ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាលនយោបាយ កថាខណ្ឌ ៦០៧។